ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៩.......សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៤

**សារាចរណែនាំ**

**ស្តីពីការកាត់ទុកពន្ធលើប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល**

អនុលោមតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លើលិខិតចុះថ្ងៃទី០៥ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធទៅនឹងការកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម ÷

១- ចាប់ពីខែសីហា ឆ្នាំ២០១៤នេះតទៅ ការកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវធ្វើឡើងដោយអគ្គនាយកដ្ឋានរតនាគារជាតិ ជារៀងរាល់ខែបន្ទាប់ពីទទួលបានទិន្នន័យនៃការគណនាប្រាក់ពន្ធនេះតាមប្រព័ន្ធគ្រប់គ្រងបៀវត្សរបស់ក្រសួងមុខងារសាធារណៈ មុនពេលបើកប្រាក់ទៅឱ្យក្រសួងស្ថាប័ននីមួយៗ។

២- ការគណនាប្រាក់ពន្ធលើប្រាក់បៀវត្ស ត្រូវផ្អែកលើមូលដ្ឋានប្រាក់បៀវត្សសរុបដោយមិនគិតបញ្ចូលប្រាក់រំលឹកឡើយ។

៣- អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវសហការផ្តល់ព័ត៌មានគ្នាទៅវិញទៅមក ក្នុងការបើកប្រាក់បៀវត្សនិងកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្សសម្រាប់ខែនីមួយៗ និងធ្វើទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ ក្នុងការផ្លាស់ប្តូរនិងផ្ទៀងផ្ទាត់ទិន្នន័យនៃប្រាក់បៀវត្សដែលជាកម្មវត្ថុនៃពន្ធលើប្រាក់បៀវត្ស។

៤- អ្នកតំណាងស្របច្បាប់ដែលមានកាតព្វកិច្ចដាក់លិខិតប្រកាសជូនសមុខឱ្យ ក្រសួង ស្ថាប័ននានា ត្រូវពិនិត្យផ្ទៀងផ្ទាត់តួលេខដែលបានកាត់ទុកជាប្រាក់ពន្ធលើប្រាក់បៀវត្ស ហើយត្រូវរៀបចំលិខិតប្រកាសពន្ធនេះដាក់ជូនរដ្ឋបាលសារពើពន្ធ ទៅតាមពេលវេលាដែលច្បាប់ស្តីពីសារពើពន្ធបានកំណត់។

ទទួលបានសារាចរណែនាំនេះ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានរតនាគារជាតិ និងគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនឹងការបង់ពន្ធលើប្រាក់បៀវត្ស មេត្តាសហការអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ - កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

Collection by VCAT Professional Consultant